# ព្រះរាជក្រឹត្យ

នស/រកត/០៨១២/៧៣៤

## ស្តីពី

## វិសោធនកម្មលើមាត្រា២ មាត្រា៥ និងមាត្រា៧ នៃព្រះរាជក្រឹត្យលេខ នស/រកត/១២០៤/០៤៨ ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០០៤ ស្តីពីការបង្កើតមូលនិធិអគ្គិសនីភាវូបនីយកម្មជនបទនៃព្រះរាជាណាចក្រកម្ពុជា និងមាត្រា៤ថ្មីនៃព្រះរាជក្រឹត្យលេខ នស/រកត/០១០៨/០៦៤ ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០០៨ ស្តីពីវិសោធនកម្មមាត្រា៤នៃព្រះរាជក្រឹត្យលេខ នស/រកត/១២០៤/០៤៨ ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០០៤ ស្តីពីការបង្កើតមូលនិធិអគ្គិសនីភាវូបនីយកម្មជនបទនៃព្រះរាជាណាចក្រកម្ពុជា

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០២០១/០៣ ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២០៤/០៤៨ ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០០៤ ស្តីពីការបង្កើតមូលនិធិអគ្គិសនីភាវូបនីយកម្មជនបទនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០១០៨/០៦៤ ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០០៨ ស្តីពីវិសោធនកម្មមាត្រា៤នៃព្រះរាជក្រឹត្យលេខ នស/រកត/១២០៤/០៤៨ ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០០៤ ស្តីពីការបង្កើតមូលនិធិអគ្គិសនីភាវូបនីយកម្មជនបទនៃព្រះរាជាណាចក្រកម្ពុជា

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL
ព្រះបរមរាជវាំង

- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

# ត្រាស់បង្គាប់

**មាត្រា មួយ.-**

មាត្រា២ មាត្រា៥ និងមាត្រា៧ នៃព្រះរាជក្រឹត្យលេខ នស/រកត/១២០៤/០៤៨ ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០០៤ ស្តីពីការបង្កើតមូលនិធិអគ្គិសនីការូបនីយកម្មជនបទនៃព្រះរាជាណាចក្រកម្ពុជា និងមាត្រា៤ថ្មី នៃព្រះរាជក្រឹត្យលេខ នស/រកត/០១០៨/០៦៤ ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០០៨ ស្តីពីវិសោធនកម្មមាត្រា៤ នៃព្រះរាជក្រឹត្យលេខ នស/រកត/១២០៤/០៤៨ ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០០៤ ស្តីពីការបង្កើតមូលនិធិអគ្គិសនីការូបនីយកម្មជនបទនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានកែសម្រួលដូចតទៅ៖

**មាត្រា ២ ថ្មី.-**

**ម.អ.ជ.** ត្រូវស្ថិតនៅក្រោមការគ្រប់គ្រងរបស់អគ្គិសនីកម្ពុជា។ **ម.អ.ជ.** មានលក្ខណៈសង្គមកិច្ច និងមានគណនីដោយឡែក។

**មាត្រា ៤ ថ្មី.-**

**ម.អ.ជ.** ត្រូវគ្រប់គ្រងដឹកនាំស្របតាមលក្ខន្តិកៈរបស់អគ្គិសនីកម្ពុជា។

**មាត្រា ៥ ថ្មី.-**

ប្រភពមូលនិធិរបស់ **ម.អ.ជ.** មានដូចខាងក្រោម៖

១- កញ្ចប់ថវិកាសង្គមកិច្ចដែលបានគ្រោងក្នុងបញ្ជីថ្លៃលក់អគ្គិសនីរបស់អគ្គិសនីកម្ពុជា និងអំណោយដទៃទៀតរបស់អគ្គិសនីកម្ពុជា ប្រសិនបើមាន។
២- អំណោយនិងជំនួយឥតសំណង ដែលប្រភពនិងលក្ខខណ្ឌនៃការផ្តល់ត្រូវបានទទួលការឯកភាពពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។
៣- ថវិកាពីរាជរដ្ឋាភិបាល។

**មាត្រា ៧ ថ្មី.-**

មាត្រា៧នៃព្រះរាជក្រឹត្យលេខ នស/រកត/១២០៤/០៤៨ ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០០៤ ស្តីពីការបង្កើតមូលនិធិអគ្គិសនីការូបនីយកម្មជនបទនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទុកជានិរាករណ៍។

**មាត្រា ២.-**

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ។

**មាត្រា ៥.-**

ព្រះរាជក្រឹត្យនេះចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ២២ ខែ សីហា ឆ្នាំ២០១២

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

នស/រកត.០៨១២/៧២១

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

ព្រះមហាក្សត្រ សូមឡាយព្រះហស្តលេខា

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជូន

សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី ដើម្បីស្នើសុំចុះហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល**

**ហត្ថលេខា**

**ស៊ុយ សែម**

**លេខៈ ៧០៩ ច.ល**

**ដើម្បីចម្លងចែក**

**រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ ៨ ឆ្នាំ២០១២**

**អគ្គលេខាធិការរងនៃរាជរដ្ឋាភិបាល**

**ស៊ុយ សុខា**

3/3